ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ក្រសួងយុត្តិធម៌

លេខ ០១៨ ប្រកស/ ដ.ន.ស.-កយ

# ប្រកាសអន្តរក្រសួង

## ស្តីពី

## នីតិវិធីនិងបែបបទនៃការធ្វើអធិការកិច្ចសំណង់

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**រដ្ឋមន្ត្រី**
**ក្រសួងយុត្តិធម៌**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ មាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងគ្រប់គ្រងការអភិវឌ្ឍអចលនវត្ថុឱ្យមានប្រសិទ្ធភាព គុណភាព សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងបរិស្ថានសម្រាប់ការរស់នៅតាមរយៈការបង្ការនិងទប់ស្កាត់អំពើល្មើសនឹងបទប្បញ្ញត្តិស្តីពីនគរូបនីយកម្មនិងសំណង់។

**ប្រការ២ .-**

ប្រកាសនេះ មានគោលដៅកំណត់អំពីនីតិវិធីនិងបែបបទនៃការធ្វើអធិការកិច្ចនៃការអភិវឌ្ឍអចលនវត្ថុ។

**ប្រការ៣ .-**

វាក្យសព្ទបច្ចេកទេសដែលប្រើក្នុងប្រកាសនេះ មានដូចខាងក្រោម÷

**១-ការធ្វើអធិការកិច្ចសំណង់** សំដៅដល់ការតាមដាន ស្រាវជ្រាវ និងត្រួតពិនិត្យការអភិវឌ្ឍអចលនវត្ថុ ដើម្បីចាត់វិធានការឬដាក់ទណ្ឌកម្មលើបុគ្គលប្រព្រឹត្តអំពើល្មើសនឹងបទប្បញ្ញត្តិស្តីពីនគរូបនីយកម្មនិងសំណង់។

**២-ការពិន័យអន្តរការណ៍** សំដៅដល់ការដាក់ទណ្ឌកម្មឱ្យបុគ្គលប្រព្រឹត្តអំពើល្មើសនឹងបទប្បញ្ញត្តិស្តីពីនគរូបនីយកម្មនិងសំណង់ បង់ប្រាក់ជូនរដ្ឋ។

**៣-ការអភិវឌ្ឍអចលនវត្ថុ** សំដៅដល់ ÷

- ការសាងសង់សំណង់ថ្មី ការជួសជុល ការសាងសង់ឡើងវិញ ការពង្រីកអគារ ការសាងសង់បន្ថែមពីលើអគារដែលមានស្រាប់ ការរុះរើ ការប្តូរមុខងារប្រើប្រាស់អគារ ការប្តូរទ្រង់ទ្រាយអគារ ការបង្កើនផ្ទៃក្រឡាកម្រាលសំណង់ និងការកែប្រែទិដ្ឋភាពខាងក្រៅនៃអគារដែលមានស្រាប់
- ការសាងសង់ឬប្តូរទ្រង់ទ្រាយអគារដែលអាចបង្កគ្រោះថ្នាក់អគ្គិភ័យ មានជាអាទិ៍ ស្ថានីយ៍ ដេប៉ូ កន្លែងស្តុក ឬចែកចាយផលិតផលតេលសិលា ឬឧស្ម័ន រោងជាងផលិតផលគ្រឿងផេះ
- ការដាក់ស្លាកសញ្ញាផ្សាយពាណិជ្ជកម្ម ការដាក់អង់តែនទូរទស្សន៍និងទូរគមនាគមន៍ក្នុងគោលបំណងធ្វើពាណិជ្ជកម្មក៏ដូចជាការដាក់រចនាសម្ព័ន្ធនៅលើដីនិងអគារ
- ការអភិវឌ្ឍដី មានដូចជា ការប្តូរប្រភេទនៃការប្រើប្រាស់ដីដើម្បីគម្រោងសាងសង់ ការកែសម្រួលក្បាលដី ការរៀបចំគម្រោងបែងចែកជាដីឡូត៍ ការកែប្រែរចនាសម្ព័ន្ធដី ការអភិវឌ្ឍទីក្រុង ការអភិវឌ្ឍតំបន់លំនៅឋានឬបុរីនិងអគារស្នាក់នៅ ការអភិវឌ្ឍតំបន់ពាណិជ្ជកម្មនិង/ឬសេវាកម្ម និងតំបន់ចម្រុះ ការអភិវឌ្ឍតំបន់ឧស្សាហកម្ម សួនឧស្សាហកម្ម និងរោងចក្រ ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង ការអភិវឌ្ឍតំបន់ទេសចរណ៍ និងការអភិវឌ្ឍនានា
- ការផ្លាស់ប្តូរលក្ខណៈគតិយុត្តផ្សេងៗទៀត មានជាអាទិ៍ ការពន្យារសុពលភាពនៃលិខិតអនុញ្ញាតដែលហួសសុពលភាព ការផ្ទេរឈ្មោះក្នុងលិខិតអនុញ្ញាត។

**៤-បទប្បញ្ញត្តិស្តីពីនគរូបនីយកម្មនិងសំណង់** សំដៅដល់វិធានពាក់ព័ន្ធនឹងការអភិវឌ្ឍអចលនវត្ថុដែលមានចែងក្នុងអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ មាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

**៥-មន្ត្រីអធិការកិច្ចសំណង់** សំដៅដល់មន្ត្រីរាជការជំនាញថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិជាវិស្វករឬស្ថាបត្យករ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលទទួលបានការតែងតាំង និងប្រគល់បេសកកម្មឱ្យចុះធ្វើអធិការកិច្ចសំណង់។

**៦-អង្គភាពមានសមត្ថកិច្ច** សំដៅដល់អគ្គនាយកដ្ឋានសំណង់ អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ។

**៧-លិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ** សំដៅដល់លិខិតអនុញ្ញាតអភិវឌ្ឍដី ឬលិខិតអនុញ្ញាតសាងសង់ ឬរុះរើ។

## ជំពូកទី២

## សមត្ថកិច្ច

**ប្រការ៤ .-**

មន្ត្រីអធិការកិច្ចសំណង់ មានដូចខាងក្រោម៖

១-ថ្នាក់ដឹកនាំជាវិស្វករឬស្ថាបត្យករនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២-មន្ត្រីជំនាញជាវិស្វករឬស្ថាបត្យករនៃអគ្គនាយកដ្ឋានសំណង់និងអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្មនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៣-មន្ត្រីជំនាញជាវិស្វករឬស្ថាបត្យករនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត។

៤-មន្ត្រីជំនាញជាវិស្វករឬស្ថាបត្យករនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ។

សមាសភាពមន្ត្រីអធិការកិច្ចសំណង់ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៣

## អធិការកិច្ចសំណង់

**ប្រការ៥ .-**

អាជ្ញាធរមានសមត្ថកិច្ច ជាអ្នកសម្រេចធ្វើអធិការកិច្ចសំណង់។

អាជ្ញាធរមានសមត្ថកិច្ច មានដូចខាងក្រោម៖

១-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះការអភិវឌ្ឍអចលនវត្ថុគ្រប់ប្រភេទនិងទំហំ។

២-អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ចំពោះការអភិវឌ្ឍអចលនវត្ថុដែលស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត។

៣-អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ចំពោះការអភិវឌ្ឍអចលនវត្ថុដែលស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

មានតែប្រធានអង្គភាពមានសមត្ថកិច្ចប៉ុណ្ណោះ ដែលអាចលើកសំណើធ្វើអធិការកិច្ចសំណង់ទៅអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ៦ .-**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអ្នកចេញលិខិតបញ្ជាបេសកកម្មចុះធ្វើអធិការកិច្ចសំណង់ ជូនមន្ត្រីអធិការកិច្ចសំណង់ថ្នាក់ជាតិ។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាអ្នកចេញលិខិតបញ្ជាបេសកកម្មចុះធ្វើអធិការកិច្ចសំណង់ ជូនមន្ត្រីអធិការកិច្ចសំណង់ថ្នាក់រាជធានី ខេត្ត តាមសំណើរបស់ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាអ្នកចេញលិខិតបញ្ជាបេសកកម្មចុះធ្វើអធិការកិច្ចសំណង់ ជូនមន្ត្រីអធិការកិច្ចសំណង់ថ្នាក់ក្រុង ស្រុក ខណ្ឌ តាមសំណើរបស់ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ។

**ប្រការ៧ .-**

រាល់ការធ្វើអធិការកិច្ចសំណង់ ត្រូវមានការចូលរួមពីមន្ត្រីអធិការកិច្ចសំណង់ចំនួន÷

- ៥ (ប្រាំ) នាក់ យ៉ាងតិច សម្រាប់ការធ្វើអធិការកិច្ចសំណង់សម្រេចដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ៣ (បី) នាក់យ៉ាងតិច សម្រាប់ការធ្វើអធិការកិច្ចសំណង់សម្រេចដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និង
- ១ (មួយ) នាក់យ៉ាងតិច សម្រាប់ការធ្វើអធិការកិច្ចសំណង់សម្រេចដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

**ប្រការ៨ .-**

មន្ត្រីអធិការកិច្ចសំណង់ អាចចូលបំពេញការងារនៅក្នុងទីតាំងណាមួយបាន លុះត្រាតែមានការយល់ព្រមពីម្ចាស់ទីតាំង។

មន្ត្រីអធិការកិច្ចសំណង់ អាចចូលបំពេញការងារនៅក្នុងការដ្ឋានសំណង់បាន លុះត្រាតែការដ្ឋានសំណង់កំពុងដំណើរការ។

មន្ត្រីអធិការកិច្ចសំណង់ អាចចូលបំពេញការងារនៅក្នុងអគារឬសំណង់ដែលបើកចំហរដល់សាធារណជនតែនៅក្នុងម៉ោងធ្វើការនៅទីតាំងនោះ។

មន្ត្រីអធិការកិច្ចសំណង់ អាចចូលបំពេញការងារនៅក្នុងទីតាំងអចលនវត្ថុឯកជន នៅក្រោយម៉ោង ៦ (ប្រាំមួយ) ព្រឹក និងមុនម៉ោង ១៨ (ដប់ប្រាំបី) ល្ងាច។

ក្នុងករណីចាំបាច់ដែលតម្រូវឱ្យមានការធ្វើអធិការកិច្ចសំណង់ នៅក្រៅម៉ោងពេលដូចមានកំណត់ក្នុងប្រការនេះ មន្ត្រីអធិការកិច្ចសំណង់ត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញា។

**ប្រការ៩ .-**

ក្នុងពេលបំពេញបេសកកម្ម មន្ត្រីអធិការកិច្ចសំណង់ត្រូវមានលិខិតបញ្ជាបេសកកម្ម ស្លៀកពាក់ឯកសណ្ឋាន និងមានសញ្ញាសម្គាល់។

**ប្រការ១០ .-**

ក្នុងពេលបំពេញបេសកកម្ម មន្ត្រីអធិការកិច្ចសំណង់ ត្រូវអនុវត្តដូចខាងក្រោម÷

- ត្រួតពិនិត្យនិងអង្កេតអំពីអនុលោមភាពនៃការអភិវឌ្ឍដី និង/ឬការងារសាងសង់ឬរុះរើសំណង់តាមលិខិតអនុញ្ញាត បទដ្ឋានបច្ចេកទេស និងបទដ្ឋានគតិយុត្តជាធរមាន
- ត្រួតពិនិត្យការប្រកបអាជីវកម្មរបស់រូបវន្តបុគ្គលឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ ក្រុមហ៊ុនសាងសង់ និងក្រុមជាងសំណង់
- ត្រួតពិនិត្យសុវត្ថិភាពការងារនៅខាងក្នុងនិងជុំវិញបរិវេណការដ្ឋានសំណង់
- ត្រួតពិនិត្យឯកសារពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍដីនិង/ឬគម្រោងសាងសង់ឬរុះរើសំណង់ ដូចជាឯកសារបញ្ជាក់កម្មសិទ្ធិឬការកាន់កាប់ដី លិខិតអនុញ្ញាតអភិវឌ្ឍដី និង/ឬលិខិតអនុញ្ញាតសាងសង់ឬរុះរើ គម្រោងប្លង់ស្ថាបត្យកម្ម លិខិតអនុញ្ញាតបើកឬបិទការដ្ឋានសាងសង់ គម្រោងប្លង់គ្រឿងផ្គុំសំណង់និងឯកសារបច្ចេកទេសពាក់ព័ន្ធ កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន និងកិច្ចសន្យាម៉ៅការសាងសង់
- ស្នើសុំឱ្យម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុផ្តល់ព័ត៌មានពាក់ព័ន្ធនឹងក្រុមហ៊ុនសិក្សាគម្រោងប្លង់ ក្រុមហ៊ុនសាងសង់ ជាងជំនាញ និង/ឬក្រុមជាងសំណង់ ដែលពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍដីនិង/ឬគម្រោងសាងសង់ឬរុះរើ
- ណែនាំឱ្យម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ធ្វើការកែតម្រូវតាមលិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ

- ណែនាំអ្នកគ្រប់គ្រងការដ្ឋានឱ្យចាត់វិធានការបន្ទាន់ដើម្បីបញ្ចៀសគ្រោះថ្នាក់ឬការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈជាយថាហេតុ នៅខាងក្នុងនិងជុំវិញបរិវេណការដ្ឋានសំណង់
- ណែនាំរូបវន្តបុគ្គលឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ និង/ឬក្រុមហ៊ុនសាងសង់ និង/ឬក្រុមជាងសំណង់អំពីបទដ្ឋានគតិយុត្តនិងបទប្បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធនឹងការអភិវឌ្ឍអចលនវត្ថុ
- ធ្វើកំណត់ហេតុនៃការចុះធ្វើអធិការកិច្ចសំណង់ និងរបាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់
- ប្រតិបត្តិការងារផ្សេងទៀត ដែលអាជ្ញាធរមានសមត្ថកិច្ចប្រគល់ជូន។

**ប្រការ១១ .-**

កំណត់ហេតុនៃការចុះធ្វើអធិការកិច្ចសំណង់ និងរបាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ ត្រូវដាក់ជូនអាជ្ញាធរមានសមត្ថកិច្ចតាមរយៈប្រធានអង្គភាពមានសមត្ថកិច្ចដើម្បីពិនិត្យ និងសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចុះធ្វើអធិការកិច្ច។

កំណត់ហេតុនៃការចុះធ្វើអធិការកិច្ចសំណង់ និងរបាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ របស់មន្ត្រីអធិការកិច្ចសំណង់ថ្នាក់ក្រោមជាតិដែលដាក់ជូនអាជ្ញាធរមានសមត្ថកិច្ចតាមរយៈប្រធានអង្គភាពមានសមត្ថកិច្ច ត្រូវចម្លងជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ១២ .-**

កំណត់ហេតុនៃការចុះធ្វើអធិការកិច្ចសំណង់ ត្រូវមានខ្លឹមសារសំខាន់ៗដូចខាងក្រោម ÷

- អត្តសញ្ញាណម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ និង/ឬរូបវន្តបុគ្គលឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ និង/ឬក្រុមហ៊ុនសាងសង់ និង/ឬក្រុមជាងសំណង់
- ព័ត៌មានអំពីគម្រោងអភិវឌ្ឍដី ឬគម្រោងសាងសង់ឬរុះរើ
- លទ្ធផលនៃការផ្ទៀងផ្ទាត់អំពីអនុលោមភាពចំពោះលិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ
- ហត្ថលេខារបស់មន្ត្រីអធិការកិច្ចសំណង់ អ្នកគ្រប់គ្រងការដ្ឋាន និង/ឬម្ចាស់សំណង់ និងអ្នកពាក់ព័ន្ធផ្សេងទៀត។

គំរូទម្រង់កំណត់ហេតុនៃការចុះធ្វើអធិការកិច្ចសំណង់ជាឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ១៣ .-**

របាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ ដែលធ្វើជូនអាជ្ញាធរមានសមត្ថកិច្ចត្រូវមានខ្លឹមសារសំខាន់ៗដូចខាងក្រោម ÷

- អត្តសញ្ញាណម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ និង/ឬរូបវន្តបុគ្គលឬក្រុមហ៊ុន

សិក្សាគម្រោងប្លង់ និង/ឬក្រុមហ៊ុនសាងសង់ និង/ឬក្រុមជាងសំណង់

- ព័ត៌មានអំពីគម្រោងអភិវឌ្ឍដី ឬគម្រោងសាងសង់ឬរះរី
- លទ្ធផលនៃការផ្ទៀងផ្ទាត់អំពីអនុលោមភាពចំពោះលិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ
- ការសន្និដ្ឋានចំពោះលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់
- ការលើកសំណើជាវិធានការនិង/ឬទណ្ឌកម្មជូនអាជ្ញាធរមានសមត្ថកិច្ចពិនិត្យនិងសម្រេច
- ហត្ថលេខារបស់មន្ត្រីអធិការកិច្ចសំណង់ និងហត្ថលេខារបស់ប្រធានអង្គភាពមានសមត្ថកិច្ច និងត្រារបស់អង្គភាពមានសមត្ថកិច្ច។

ក្នុងករណីមន្ត្រីអធិការកិច្ចសំណង់លើកសំណើធ្វើការពិន័យអន្តរការណ៍ របាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ ត្រូវមានខ្លឹមសារបន្ថែមដូចខាងក្រោម÷

- ប្រភេទអំពើល្មើសដោយមានបញ្ជាក់អំពីទំហំ រយៈពេល ផលប៉ះពាល់ និងព័ត៌មានចាំបាច់ផ្សេងទៀត
- អត្តសញ្ញាណម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ និង/ឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ និង/ឬក្រុមហ៊ុនសាងសង់ ដែលប្រព្រឹត្តអំពើល្មើស
- បទប្បញ្ញត្តិដែលកំណត់អំពីការពិន័យអន្តរការណ៍
- ចំនួនទឹកប្រាក់ដែលត្រូវពិន័យអន្តរការណ៍។

គំរូទម្រង់របាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ជាឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ១៤ .-**

ក្នុងករណីពិនិត្យឃើញថា ការអភិវឌ្ឍអចលនវត្ថុកំពុងដំណើរការដោយមិនអនុលោមតាមលិខិតអនុញ្ញាត បទដ្ឋានបច្ចេកទេស និងបទដ្ឋានគតិយុត្តជាធរមាន របាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ ត្រូវលើកសំណើចាត់វិធានការនិង/ឬដាក់ទណ្ឌកម្មមួយឬច្រើនដូចខាងក្រោម÷

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការផ្អាកការដ្ឋានសាងសង់
- ការព្យួរឬដកលិខិតអនុញ្ញាតអភិវឌ្ឍដី និង/ឬលិខិតអនុញ្ញាតសាងសង់ឬរះរី លិខិតអនុញ្ញាតបើកឬបិទការដ្ឋានសាងសង់ ឬវិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មសាងសង់
- ការហាមឃាត់ការប្រើប្រាស់ ឬធ្វើអាជីវកម្មពាក់ព័ន្ធនឹងសំណង់
- ការឃាត់ទុកជាបណ្តោះអាសន្នសម្ភារ ផលិតផល បរិក្ខារ និង/ឬគ្រឿងចក្រពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើល្មើស

- ការបង្ខំឱ្យរុះរើឬស្ថាបនាឡើងវិញឱ្យដូចស្ថានភាពដើម នូវអ្វីដែលប្រែប្រួលឬបាត់បង់ដោយអំពើល្មើស
- ការពិន័យអន្តរការណ៍ចំពោះបុគ្គលប្រព្រឹត្តអំពើល្មើស
- ការចាត់វិធានការផ្សេងទៀតស្របតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ១៥ .-**

អាជ្ញាធរមានសមត្ថកិច្ច ត្រូវសម្រេចចាត់វិធានការ និង/ឬដាក់ទណ្ឌកម្មចំពោះបុគ្គលប្រព្រឹត្តអំពើល្មើសដោយផ្អែកលើកំណត់ហេតុនៃការចុះធ្វើអធិការកិច្ចសំណង់ និងរបាយការណ៍ស្ដីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើរបាយការណ៍នោះ។

ក្នុងករណីបុគ្គលមិនអនុវត្តវិធានការនិង/ឬទណ្ឌកម្មដែលអាជ្ញាធរមានសមត្ថកិច្ចបានតម្រូវ អាជ្ញាធរមានសមត្ថកិច្ចត្រូវរៀបចំសំណុំរឿងបញ្ជូនទៅតុលាការដើម្បីស្នើសុំចាត់វិធានការអនុវត្តដោយបង្ខំ។

**ប្រការ១៦ .-**

មន្ត្រីអធិការកិច្ចសំណង់ មិនត្រូវធ្វើសកម្មភាពដូចខាងក្រោម÷

- បង្កឱ្យមានការប៉ះពាល់ឬរាំងស្ទះដល់ដំណើរការអភិវឌ្ឍ ឬសាងសង់ ឬរុះរើ ដែលអនុលោមតាមលិខិតអនុញ្ញាត បទប្បញ្ញត្តិបច្ចេកទេស និងបទដ្ឋានគតិយុត្តជាធរមាន នៅក្នុងពេលបំពេញសកម្មភាពអធិការកិច្ចរបស់ខ្លួន
- ផ្សព្វផ្សាយជាសាធារណៈអំពីព័ត៌មានដែលពាក់ព័ន្ធនឹងបច្ចេកទេសសាងសង់ និងកិច្ចសន្យាម៉ៅការសាងសង់។

**ប្រការ១៧ .-**

នៅអំឡុងពេលនៃការធ្វើអធិការកិច្ចសំណង់ ម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ និង/ឬរូបវន្តបុគ្គល ឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ និង/ឬក្រុមហ៊ុនសាងសង់ និង/ឬក្រុមជាងសំណង់ និង/ឬតំណាងមានកាតព្វកិច្ច ដូចខាងក្រោម÷

- ផ្ដល់កិច្ចសហការប្រកបដោយសុឆន្ទៈក្នុងការធ្វើអធិការកិច្ចសំណង់
- អនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចសំណង់ ចូលត្រួតពិនិត្យគ្រប់ទីកន្លែងទាំងអស់នៅក្នុងការដ្ឋាន
- មិនរារាំង ហាមឃាត់ ឬបង្កការលំបាកដល់ការធ្វើអធិការកិច្ចសំណង់

- មានវត្តមាននៅក្នុងពេលប្រតិបត្តិការអធិការកិច្ចសំណង់ តាមសំណើរបស់មន្ត្រីអធិការកិច្ចសំណង់
- ផ្តល់ព័ត៌មានទូទៅពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍអចលនវត្ថុ តាមសំណើរបស់មន្ត្រីអធិការកិច្ចសំណង់ ជាអាទិ៍អំពីគ្រប់ភាគីពាក់ព័ន្ធនឹងការអនុវត្តគម្រោង
- ឆ្លើយបំភ្លឺ ពន្យល់ ផ្តល់ព័ត៌មាននិងឯកសារ ឬផ្តល់សេចក្តីអះអាងពាក់ព័ន្ធនឹងការគោរព និងអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអភិវឌ្ឍអចលនវត្ថុរបស់ខ្លួន ប្រកបដោយសីលធម៌ សុចរិតភាព និងការទទួលខុសត្រូវ
- ចាត់វិធានការសមស្របដើម្បីធានាសន្តិសុខ និងសុវត្ថិភាពរបស់មន្ត្រីអធិការកិច្ចសំណង់ ក្នុងពេលបំពេញការងារអធិការកិច្ចនៅក្នុងទីតាំងគម្រោង ឬការដ្ឋានសាងសង់ ឬសំណង់របស់ខ្លួន
- ផ្តល់នូវសំណាកនៃសម្ភារ បរិក្ខារ ផលិតផលសំណង់ ឧបករណ៍ ឬគ្រឿងចក្រផ្សេងទៀត ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យនិងការធ្វើវិភាគផ្ទៀងផ្ទាត់។

**ប្រការ១៨ .-**

ក្នុងពេលប្រតិបត្តិការអធិការកិច្ចសំណង់ ម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ ឬវិស្វករ/វិប្បន្នបុគ្គល ឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ ឬក្រុមហ៊ុនសាងសង់ ឬក្រុមជាងសំណង់ ឬតំណាងមានសិទ្ធិដូចខាងក្រោម÷

- ស្នើសុំមន្ត្រីអធិការកិច្ចសំណង់បង្ហាញលិខិតបញ្ជាបេសកកម្ម
- ស្នើសុំមន្ត្រីអធិការកិច្ចសំណង់ កត់ត្រារាល់ការឆ្លើយតបឬសេចក្តីអះអាងរបស់ខ្លួននៅក្នុងកំណត់ហេតុនៃការធ្វើអធិការកិច្ចសំណង់
- ទទួលបានច្បាប់ចម្លងនៃកំណត់ហេតុអធិការកិច្ចសំណង់។

## ជំពូកទី៤
## បណ្តឹងតវ៉ា

**ប្រការ១៩ .-**

បុគ្គលដែលមិនសុខចិត្តចំពោះការចាត់វិធានការ និង/ឬដាក់ទណ្ឌកម្មរបស់អាជ្ញាធរមានសមត្ថកិច្ចធ្វើអធិការកិច្ចសំណង់ អាចធ្វើបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរនោះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច ឬបានទទួលដំណឹងអំពីសេចក្តីសម្រេចចាត់វិធានការ និង/ឬដាក់ទណ្ឌកម្ម។ អាជ្ញាធរមានសមត្ថកិច្ចធ្វើអធិការកិច្ចសំណង់ ត្រូវធ្វើការសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីថ្ងៃទទួលពាក្យបណ្តឹងតវ៉ា។

ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ចធ្វើអធិការកិច្ចសំណង់ មិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលកំណត់ដូចមានចែងក្នុងប្រការនេះ ម្ចាស់បណ្តឹងអាចធ្វើបណ្តឹងតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ចធ្វើអធិការកិច្ចសំណង់តាមឋានានុក្រម ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃគិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

ម្ចាស់បណ្តឹងអាចធ្វើបណ្តឹងតវ៉ាចំពោះការសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចធ្វើអធិការកិច្ចសំណង់តាមឋានានុក្រម ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃគិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច ឬបានទទួលដំណឹងអំពីសេចក្តីសម្រេចលើបណ្តឹងតវ៉ារបស់ខ្លួន។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុនៃការសម្រេចរបស់ខ្លួនលើបណ្តឹងតវ៉ា ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

ក្នុងករណីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនសម្រេចលើបណ្តឹងតវ៉ាម្ចាស់បណ្តឹងមានសិទ្ធិប្តឹងទៅតុលាការ។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុនៃការសម្រេចរបស់ខ្លួនលើបណ្តឹងតវ៉ា ក្នុងរយៈពេល ២៥ (ម្ភៃប្រាំ) ថ្ងៃ យ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុនៃការសម្រេចរបស់ខ្លួនលើបណ្តឹងតវ៉ា ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ យ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

ក្នុងករណីបុគ្គលប្រព្រឹត្តអំពើល្មើសមិនបង់ប្រាក់ពិន័យអន្តរការណ៍ អាជ្ញាធរមានសមត្ថកិច្ចត្រូវចងក្រងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូង នៅពេលផុតរយៈពេលនៃបណ្តឹងតវ៉ាដូចមានកំណត់ក្នុងប្រការនេះ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**ប្រការ២០ .-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមិនទាន់មានប្លង់គោលប្រើប្រាស់ដី អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ នោះ គ្មានសមត្ថកិច្ចសម្រេចធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការអភិវឌ្ឍដីទេ។ ក្នុងករណីនេះ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាអាជ្ញាធរមានសមត្ថកិច្ចសម្រេចធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការអភិវឌ្ឍដីនោះ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដែលមិនទាន់មានសមត្ថកិច្ចចេញលិខិតអនុញ្ញាតសាងសង់ ជួសជុល និងរុះរើ និងលិខិតអនុញ្ញាតបើកនិងបិទការដ្ឋាន គ្មានសមត្ថកិច្ចសម្រេចធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការងារសាងសង់ឬរុះរើទេ។ ក្នុងករណីនេះ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាអាជ្ញាធរមានសមត្ថកិច្ចសម្រេចធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការងារសាងសង់ឬរុះរើ តាមសំណើរបស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ២១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២២ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងយុត្តិធម៌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ២ កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ជា សុផារ៉ា

**រដ្ឋមន្ត្រី**
**ក្រសួងយុត្តិធម៌**

អង្គ វង្ស វឌ្ឍានា

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ២២ "ដើម្បីមុខការ"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ..១១៨ ប្រ.ក./ដ.ន.ស.ក.សណ..ចុះថ្ងៃទី..០២...ខែ..សីហា..ឆ្នាំ២០១៩ ស្ដីពី
នីតិវិធីនិងបែបបទនៃការធ្វើអធិការកិច្ចសំណង់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

..................................................[1]

**កំណត់ហេតុ**

**ស្តីពី**

**ការចុះធ្វើអធិការកិច្ចសំណង់**

ឆ្នាំ...........ពុទ្ធស័ករាជពីរពាន់ប្រាំរយ........ខែ........ឆ្នាំ.......ត្រូវនឹងឆ្នាំពីរពាន់.......ខែ..........ថ្ងៃ...........ក្រុមមន្ត្រីអធិការកិច្ចសំណង់របស់[2] សហការជាមួយរដ្ឋបាល...........បានចុះធ្វើអធិការកិច្ចសំណង់ នៅការដ្ឋាន..........គម្រោង...........តំណាងដោយលោក/លោកស្រី..............ដែលមានទីតាំងស្ថិតនៅដីឡូត៍លេខ........ផ្លូវ..........ភូមិ..........ឃុំ/ សង្កាត់...........ក្រុង/ស្រុក.............រាជធានី/ខេត្ត............... ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ/បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ........................ចុះថ្ងៃទី.......ខែ..............ឆ្នាំ........................។

ទី ១. ក្រុមការងារបានចុះពិនិត្យការដ្ឋានសាងសង់ឃើញថា÷

- លិខិតអនុញ្ញាតសាងសង់.................................................................................................
- លិខិតអនុញ្ញាតបើកការដ្ឋានសាងសង់..............................................................................
- ការហ៊ុំព័ទ្ធការដ្ឋានសាងសង់...........................................................................................
- អនាម័យការដ្ឋានសាងសង់...............................................................................................
- លក្ខណៈនគរូបនីយប្បញ្ញត្តិ÷

| នគរូបនីយប្បញ្ញត្តិ | ប្លង់អនុញ្ញាតដោយក្រសួង | សាងសង់ជាក់ស្ដែង | មតិវាយតម្លៃ |
|---|---|---|---|
| ក. ថ្នាតម្លាតអគារ | | | |
| ថ្នាតម្លាតខាង........... | ______ម៉ែត្រ | ______ម៉ែត្រ | |
| ថ្នាតម្លាតខាង........... | ______ម៉ែត្រ | ______ម៉ែត្រ | |
| ថ្នាតម្លាតខាង........... | ______ម៉ែត្រ | ______ម៉ែត្រ | |
| ថ្នាតម្លាតខាង........... | ______ម៉ែត្រ | ______ម៉ែត្រ | |

[1] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសាលារាជធានី ខេត្ត ឬសាលាក្រុង ស្រុក ខណ្ឌ

[2] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសាលារាជធានី ខេត្ត ឬសាលាក្រុង ស្រុក ខណ្ឌ

| ខ. កម្ពស់អគារ | | | |
|---|---|---|---|
| គិតជាជាន់ | | | |
| គិតជាម៉ែត្រ | | | |
| **គ. មុខងារប្រើប្រាស់អគារ** | | | |
| មុខងារប្រើប្រាស់អគារ | | | |
| **ឃ. ចំណតរថយន្ត** | | | |
| ចំណតរថយន្តតូច | | | |
| ចំណតរថយន្តធំ | | | |
| **ង. ហេដ្ឋារចនាសម្ព័ន្ធ** | | | |
| អាងប្រព្រឹត្តកម្មទឹកកខ្វក់ | | | |
| អាងបង្គន់អនាម័យ | | | |
| ប្រព័ន្ធលូ | | | |
| ប្រព័ន្ធពន្លត់អគ្គិភ័យ | | | |
| ស្នូនជ្រាបទឹក | | | |
| **ច. បទប្បញ្ញត្តិពាក់ព័ន្ធ** | | | |
| | | | |
| | | | |
| | | | |

**ទី ២. មតិក្រុមការងារចុះពិនិត្យ÷**

..........................................................................................................................................

**ទី ៣. ក្រុមការងារបានណែនាំ និងបានតម្រូវឱ្យម្ចាស់សំណង់អនុវត្តតាមសេចក្ដីណែនាំដូចខាងក្រោម÷**

១. អនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតអនុញ្ញាតសាងសង់ លិខិតបើកការដ្ឋានសាងសង់ និងបទដ្ឋានគតិយុត្តនគរូបនីយកម្ម និងសំណង់។

២. សេចក្ដីណែនាំ និងវិធានការ..........................................................................................

**ទី ៤. ម្ចាស់សំណង់បានស្ដាប់ បានអាន និងបានឯកភាពអនុវត្តតាមសេចក្ដីណែនាំ និងវិធានការ ដូចមានចែងក្នុងចំណុច ទី៣ ខាងលើ។**

**ឈ្មោះ** **តួនាទី** **ហត្ថលេខា/ ស្នាមមេដៃ**

១.........................................................................................................................................

២.........................................................................................................................................

ទី ៥. សមាសភាពក្រុមការងារចុះត្រួតពិនិត្យ រួមមាន÷

| ឈ្មោះ | តួនាទី | ហត្ថលេខា |
|---|---|---|

១...........................................................................................................................

២...........................................................................................................................

ការចុះត្រួតពិនិត្យនេះ ត្រូវបានបញ្ចប់នៅវេលាម៉ោង.......................... នាទី.................. នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសរីករាយ និងទទួលខុសត្រូវខ្ពស់៕

ថ្ងៃ..................................ខែ............ឆ្នាំ...........................ព.ស. ២៥..........

ធ្វើនៅ............................ ថ្ងៃទី.......... ខែ........... ឆ្នាំ២០....

**អ្នកធ្វើកំណត់ហេតុ**

**ឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ...១១៨ ប្រក/ដនសណ.ក.សរ...ចុះថ្ងៃទី...០២...ខែ...សីហា...ឆ្នាំ២០១៩ ស្តីពី**
**នីតិវិធីនិងបែបបទនៃការធ្វើអធិការកិច្ចសំណង់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

...........................................................................[១]

លេខ:..........................ពអ/.......

**សូមគោរពជូន**

.........................................................................................................................................[២]

**តាមរយៈ÷** ...............................................................................................................................[៣]

**កម្មវត្ថុ** ÷ របាយការណ៍ស្តីពីលទ្ធផលនៃចុះធ្វើអធិការកិច្ចសំណង់ នៅការដ្ឋាន............គម្រោង....................................
តំណាងដោយលោក/លោកស្រី..............................ដែលមានទីតាំងស្ថិតនៅ..........................................

**យោង** ÷-លិខិតបញ្ជាបេសកកម្មលេខ..........................................ចុះថ្ងៃទី..........ខែ.............ឆ្នាំ......................
-បណ្តឹងតវ៉ាចុះថ្ងៃទី.............ខែ.............ឆ្នាំ..................របស់...................................................

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមអនុញ្ញាតគោរពជម្រាបជូន[៤] មេត្តាជ្រាបថា កាលពីថ្ងៃទី...........ខែ.............ឆ្នាំ................វេលាម៉ោង..................ក្រុមមន្ត្រីអធិការកិច្ចសំណង់ ដឹកនាំដោយ..................
បានចុះធ្វើអធិការកិច្ចនៅការដ្ឋាន....................................គម្រោង...............................របស់លោក........................
ឬក្រុមហ៊ុន.......................... តំណាងដោយលោក/លោកស្រី..........................ដែលមានទីតាំងស្ថិតនៅ................។

**ក-សមាសភាពចូលរួម÷**

១-លោក...........................តួនាទី.................................
២-លោក...........................តួនាទី.................................

---

[១] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសាលារាជធានី ខេត្ត ឬសាលាក្រុង ស្រុក ខណ្ឌ

[២] រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

[៣] អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់ ឬអគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម ឬប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ឬប្រធានការិយាល័យការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ

[៤] រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

**ខ-លទ្ធផលនៃការធ្វើអធិការកិច្ច÷**

ក្រុមហ៊ុនឬលោក.....................ជាម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ លើគម្រោង...........................។

ក្រោយការពិនិត្យផ្ទៀងផ្ទាត់គម្រោង...................................................មានកំហុសឆ្គង ដូចខាងក្រោម÷

១..................................................................................................................................

២..................................................................................................................................

**គ-សន្និដ្ឋាន ÷**

ក្រុមហ៊ុនឬលោក..................ជាម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ បានប្រព្រឹត្តអំពើល្មើសដូចខាងក្រោម÷

១-ធ្វើការសាងសង់ឬរុះរើ ឬអភិវឌ្ឍ..................ល្មើសនឹងមាត្រា.........នៃអនុក្រឹត្យលេខ.......................

២-ធ្វើការសាងសង់ឬរុះរើ ឬអភិវឌ្ឍ..................ល្មើសនឹងមាត្រា........នៃអនុក្រឹត្យលេខ.......................

**ឃ-មតិ÷**

គួរសម្រេចឱ្យលោកឬក្រុមហ៊ុន........................... តំណាងដោយលោក/លោកស្រី ..........................

ជាម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ÷

១-បង់ប្រាក់ពិន័យអន្តរការណ៍ចំនួន................តាមមាត្រា.........នៃអនុក្រឹត្យលេខ............................។

២-សម្រេចចាត់វិធានការ............................តាមមាត្រា.........នៃអនុក្រឹត្យលេខ............................។

ថ្ងៃ............................ខែ....................ឆ្នាំ..........................ព.ស. ២៥...........

ធ្វើនៅ............................ថ្ងៃទី............ ខែ............ឆ្នាំ ២០......

**អ្នកធ្វើរបាយការណ៍**

**បានឃើញនិងឯកភាព**

សូមគោរពជូន[៥] មេត្តាពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់។

សូមគោរពជូន[៦] មេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំបាទ។

ថ្ងៃ............................ខែ....................ឆ្នាំ..........................ព.ស. ២៥...........

ធ្វើនៅ............................ថ្ងៃទី............ ខែ............ឆ្នាំ ២០......

.............................[៧]

---

[៥] រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

[៦] រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

[៧] អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់ ឬអគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម ឬប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ឬប្រធានការិយាល័យការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ